# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៤.០៦៣/០៨ គ.ជ.ប.អគ្គ.ពស** ភ្នំពេញថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០០៨

# វគ្គបណ្តុះបណ្តាល ស្តីពីការឃោសនាបោះឆ្នោត

នៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០០៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល និងមន្ត្រី គ.ជ.ប ស្តីពីការឃោសនាបោះឆ្នោត ។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល ២ថ្ងៃ គឺនៅថ្ងៃទី ២៨-២៩ ខែមេសា ឆ្នាំ២០០៨ នាទីស្តីការ គ.ជ.ប ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានមតិសំណេះសំណាលក្នុងពិធីបើកវគ្គថា នេះគឺជាការបណ្តុះបណ្តាលអំពីការឃោសនាបោះឆ្នោត ដែលជាចំណុចក្តៅមួយដែលយើងអាចនិយាយបានថា ជាដំណាក់កាលមានទំនាស់ច្រើនបើប្រៀបធៀបទៅនឹងដំណាក់កាលផ្សេងៗនៃការរៀបចំការបោះឆ្នោត ។

វគ្គបណ្តុះបណ្តាលនេះ ក៏បានផ្តោតផងដែរទៅលើចំនុចសំខាន់ៗមួយចំនួនដូចជា ÷

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ការងារសន្តិសុខ ក្រមសីលធមិសម្រាប់កងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ
- ក្រមសីលធមិសម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ
- ក្រមសីលធមិសម្រាប់អ្នកសង្កេតការណ៍ និងសម្រាប់មន្ត្រីបោះឆ្នោត
- នីតិវិធីដោះស្រាយបណ្តឹងសម្រាប់ការបោះឆ្នោត និងការងារអប់រំសាធារណជន ។

ឯកឧត្តបានបន្តថា លោកគ្រូ អ្នកគ្រូត្រូវស្វែងយល់ថែមទៀតទាក់ទងនឹងការបោះឆ្នោត ព្រោះថាយើងចេញទៅបង្រៀនបន្តដល់ គខ/កប ឬចេញទៅបង្រៀនខេត្ត ក្រុងនោះ អាចមានសំនួរជាច្រើនទាក់ទងនៃការបោះឆ្នោតទាំងមូល មិនមែនទាក់ទងត្រឹមតែការឃោសនាប៉ុណ្ណោះទេ ។ លោកគ្រូ អ្នកគ្រូត្រូវយកអ្វីដែលបានបរៀន ទៅបង្រៀនបន្តទៀតដល់ថ្នាក់ខេត្ត ក្រុង ហើយថ្នាក់ខេត្ត ក្រុងបង្រៀនបន្តដល់ថ្នាក់ឃុំ សង្កាត់ ព្រោះថាអ្នកអនុវត្តជាក់ស្តែង អ្នកសម្របសម្រួលការឃោសនាបោះឆ្នោត គឺគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលនេះ មានចំនួន ៤១នាក់ រួមមានគ្រូបង្គោល គ.ជ.ប ចំនួន ២៤នាក់ និងមន្ត្រីជំនាញនៅតាមនាយកដ្ឋាន គ.ជ.ប ចំនួន ១៧នាក់ ។

សូមបញ្ជាក់ថា នៅថ្ងៃទី ៨-៩ ខែឧសភា ឆ្នាំ២០០៨ ខាងមុខនេះ គ.ជ.ប នឹងមានបើកវគ្គបណ្តុះបណ្តាលដល់សិក្ខាកាមដែលជាមន្ត្រីបោះឆ្នោតនៅទូទាំង ២៤ ខេត្ត ក្រុង រួមទាំងតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតផងដែរ ។